# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៥៧ សសរ.កសក

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់ថ្លៃឈ្នួលដែននេសាទសមុទ្រ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈឬការជួលតាមការព្រមព្រៀងនិងការបង់ថ្លៃឈ្នួលនេសាទ
- បានឃើញប្រកាសលេខ៦៣០ ប្រក.កសក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនិងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

# សម្រេច

**ប្រការ ១** : ត្រូវបានកំណត់ថ្លៃឈ្នួលនេសាទសមុទ្រ តាមប្រភេទឧបករណ៍នេសាទសម្រាប់អនុវត្តក្នុងឆ្នាំ២០១៤ ដូចមានក្នុងតារាងខាងក្រោម :

| ល.រ | ឈ្មោះ ឧបករណ៍នេសាទ | ក្រឡា | ឯកត្តា | ថ្លៃឈ្នួលដែននេសាទ |
|---|---|---|---|---|
| ១ | មងក្ដាម លើសពី៥០០ម៉ែត្រ | ៦ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ២ | មងបង្គា៣ជាន់ លើសពី៥០០ម៉ែត្រ | ៣,៨ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៣ | មងបង្គា១ជាន់ លើសពី៥០០ម៉ែត្រ | ៣,៥ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៤ | មងត្រីកាតាំង លើសពី៥០០ម៉ែត្រ | ៦ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៥ | មងត្រីក្បក លើសពី៥០០ម៉ែត្រ | ៣,៥ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៦ | មងត្រីកាម៉ុង លើសពី៥០០ម៉ែត្រ | ៤ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៧ | មងត្រីបេកា លើសពី៥០០ម៉ែត្រ | ៨ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៨ | មងត្រីថ្មោង លើសពី៣០០ម៉ែត្រ | ២,៥ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ៩ | មងហ៊ុមកៀនច្រាំង លើសពី៧០ម៉ែត្រ | ៣ស.មឡើង | ១ ម៉ែត្រ | ១.៥០០៛០០ |
| ១០ | អួនហ៊ុមកៀនច្រាំង | | ១ ម៉ែត្រ | ១.៥០០៛០០ |
| ១១ | អួនហ៊ុម | | ១ ម៉ែត្រ | ១.៥០០៛០០ |
| ១២ | មងត្រីកាវ៉ាវ លើសពី៥០០ម៉ែត្រ | ៧ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ១៣ | មងត្រីស លើសពី៥០០ម៉ែត្រ | ២ស.មឡើង | ១ ម៉ែត្រ | ២០០៛០០ |
| ១៤ | មងហ៊ុម លើសពី២៥០ម៉ែត្រ | ៣ស.មឡើង | ១ ម៉ែត្រ | ១.៥០០៛០០ |
| ១៥ | លបក្ដាម លើសពី២០០លប | ៦ស.មឡើង | ១ លប | ៥០០៛០០ |
| ១៦ | ឈ្នក់ក្ដាម លើសពី៥០ឈ្នក់ | | ១ ឈ្នក់ | ១.០០០៛០០ |
| ១៧ | លបមឹកធ្វើពីឈើ លើសពី៥០លប | ៤ស.មឡើង | ១ លប | ១.៥០០៛០០ |
| ១៨ | លបខ្យង លើសពី២០លប | | ១ លប | ១.៥០០៛០០ |
| ១៩ | លបត្រី មានមុខកាត់តូចជាង១ម៉ែត្រ | លើសពី១៥លប | ១ លប | ៥.០០០៛០០ |
| ២០ | លបត្រី មានមុខកាត់ធំជាង១ ម៉ែត្រ | លើសពី១៥លប | ១ លប | ៣០.០០០៛០០ |
| ២១ | អួនខ្វៅ ( មងខ្វៅ ) លើសពី២០០ម៉ែត្រ | ៣ស.មឡើង | ១ ម៉ែត្រ | ៣.៥០០៛០០ |
| ២២ | ផ្លាក់មឹកសំបកខ្យងលើសពី១.០០០ខ្យង | | ១ ខ្យង | ១០០៛០០ |
| ២៣ | សន្ទូចបបែល លើសពី១.០០០ផ្លែ | | ១ ផ្លែ | ១០០៛០០ |
| ២៤ | សន្ទូចរនង លើសពី៥០០ផ្លែ | | ១ ផ្លែ | ៥០០៛០០ |
| ២៥ | សំណាញ់ បណ្ដោយលើសពី៦ម៉ែត្រ | | ១ វង់ | ៥.០០០៛០០ |
| ២៦ | ប៉ុក | | ១ ប៉ុក | ៨៦០.០០០៛០០ |
| ២៧ | ផ្ទុងផាងបង្គា | | ១ មាត់ | ៥០.០០០៛០០ |
| ២៨ | ផ្ទុងផាងគី | | ១ មាត់ | ២៥.០០០៛០០ |

| | | | | |
|---|---|---|---|---|
| ២៩ | ឈ្នាងអូសគ្រំគ្រឡាហូល | | ១ សេះ | ២៧.០០០៛០០ |
| ៣០ | ឈ្នាងអូសក្រែងឈាម | | ១ សេះ | ៤០.០០០៛០០ |
| ៣១ | អួនទិត និងអួនផ្សេងៗ | | ១ ម៉ែត្រ | ៤.៦០០៛០០ |
| ៣២ | អួនអូស | | ១ សេះ | ២៧.០០០៛០០ |

**ប្រការ ២ :** សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានរដ្ឋបាលជលផល នាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ នាយខណ្ឌរដ្ឋបាលជលផលគ្រប់ខេត្តដែលមានដែននេសាទសមុទ្រ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- សាលាខេត្តពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ